# ការទទួលយកការទទួលខុសត្រូវ

| | | |
|---|---|---|
| **ដាវីឌ**<br><br>ពួកសាសន៍អ៊ីស្រាអែលត្រូវបានគំរាមកំហែងដោយពួកភីលីស្ទីន និងកូលីយ៉ាតដែលមានមាឌធំ ។ ( សូមមើល សាំយូអែល ទី១ ១៧:៣–៩, ១៦ ) ។ | សូមអាន សាំយូអែល ទី១ ១៧:២៤–២៥ ។<br><br>តើពួកបុរសពីអ៊ីស្រាអែលអាចដោះសារអ្វីខ្លះដើម្បីមិនប្រយុទ្ធនឹងកូលីយ៉ាត ? | សូមអាន សាំយូអែល ទី១ ១៧:៣២, ៣៧–៤០ ។<br><br>តើគុណលក្ខណៈអ្វីខ្លះរបស់ព្រះអង្គសង្គ្រោះដែលអ្នកឃើញដាវីឌមាន នៅពេលលោកទទួលយកការទទួលខុសត្រូវដើម្បីប្រយុទ្ធប្រឆាំងនឹងកូលីយ៉ាត ? |
| **រឿងប្រៀបប្រដូចអំពីប្រាក់**<br><br>បុរសម្នាក់ ( និមិត្តរូបឲ្យព្រះអង្គសង្គ្រោះ ) បានផ្ដល់ឲ្យបុរសបីនាក់នូវចំនួនទេពកោសល្យផ្សេងគ្នាៗ ( ប្រាក់ ) ចេញពីលុយរបស់គាត់ផ្ទាល់ ។ គាត់បានត្រឡប់មកវិញនៅពេលក្រោយដើម្បីឲ្យពួកគេប្រាប់គាត់នូវអ្វីដែលពួកគេបានធ្វើជាមួយនឹងប្រាក់ទាំងនោះ ។ ( សូមមើល ម៉ាថាយ ២៥:១៤–១៥, ១៩ ) ។ | សូមអាន ម៉ាថាយ ២៥:១៨, ២៤–២៨ ។<br><br>តើបុរសដែលមានប្រាក់មួយពាន់ដោះសារអ្វីខ្លះសម្រាប់ការមិនវិនិយោគប្រាក់របស់គាត់ ? តើគាត់ទទួលលទ្ធផលអ្វីខ្លះ ? | សូមអាន ម៉ាថាយ ២៥:១៦–១៧, ២០–២៣ ។<br><br>តើអ្នកឃើញបុរសពីរនាក់ដំបូងបង្ហាញគុណលក្ខណៈរបស់ព្រះអង្គសង្គ្រោះអ្វីខ្លះ នៅពេលពួកគេទទួលខុសត្រូវផ្ទាល់ខ្លួនចំពោះអ្វីដែលបានផ្ដល់ដល់ពួកគេ ? តើពួកគេទទួលបានរង្វាន់ដោយរបៀបណា ? |

**ខ្ញុំ**

សូមឆ្លើយសំណួរពីរក្នុងចំណោមសំណួរខាងក្រោមនេះ ៖

១. តើមានអ្វីខ្លះដែលខ្ញុំធ្វើជាញឹកញាប់ដើម្បីបង្ហាញថា ខ្ញុំកំពុងទទួលខុសត្រូវចំពោះការរៀនសូត្ររបស់ខ្ញុំ ?

២. តើការដោះសារអ្វីខ្លះដែលខ្ញុំអាចលុបបំបាត់ក្នុងជីវិតរបស់ខ្ញុំ ដើម្បីទទួលខុសត្រូវកាន់តែច្រើនចំពោះការរៀនសូត្ររបស់ខ្ញុំ ?

៣. តើគុណលក្ខណៈអ្វីខ្លះរបស់ព្រះអង្គសង្គ្រោះដែលខ្ញុំអាចអភិវឌ្ឍ ដើម្បីជួយខ្ញុំទទួលខុសត្រូវចំពោះការរៀនសូត្ររបស់ខ្ញុំ ?

៤. តើខ្ញុំអាចធ្វើអ្វីបានដើម្បីយាងអញ្ជើញព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ឲ្យជួយខ្ញុំក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្ញុំ ?

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© 2024 by Intellectual Reserve, Inc. All rights reserved. PD80023177_258_193_handout